# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## សេចក្តីប្រកាសពត៌មាន

# ស្នាដៃសិល្បៈខ្មែរដ៏វិចិត្រត្រូវបានបើកសម្ពោធ ដាក់តាំងបង្ហាញនៅវិចិត្រសាលជាតិអូស្ត្រាលី

រូបចម្លាក់ដ៏ស្រស់ស្អាតរបស់ខ្មែរចំនួនបី ដែលមានចំណាស់ប្រាំសតវត្សមកហើយនោះ ត្រូវបានបើកសម្ពោធសំរាប់ការទស្សនានាថ្ងៃនេះ នៅវិចិត្រសាលជាតិអូស្ត្រាលី។ រូបចម្លាក់នេះនឹងដាក់តាំងបង្ហាញក្នុងរយៈពេលបីឆ្នាំបន្ទាប់ ក្រោមកម្ចីរយៈពេលវែងពីសារមន្ទីរជាតិកម្ពុជា។

ឯកឧត្តម **ហាប់ ទូច** អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលបានធ្វើដំណើរទៅកាន់ទីក្រុងកង់បេរ៉ា ដើម្បីចូលរួមក្នុងពិធីសម្ពោធនេះ បានមានប្រសាសន៍ថា«វិចិត្រសាលជាតិអូស្ត្រាលី និងសារមន្ទីជាតិកម្ពុជាបានភ្ជាប់ទំនាក់ទំនងអស់បីទសវត្សមកហើយ ហើយយើងរំពឹងនឹងរឹតបន្តឹងចំណងសហប្រតិបត្តិការនាពេលអនាគត។»

ប្រធានវិចិត្រសាលជាតិអូស្ត្រាលី បណ្ឌិត **រ៉ុន រ៉ាដហ្វដ** (**Ron Radford**) បានមានប្រសាសន៍ថា «ខ្ញុំមានសេចក្តីរីករាយក្រៃលែង ដោយបានឃើញនូវស្នាដៃដ៏អស្ចារ្យត្រូវបានដាក់តាំងបង្ហាញនៅទីក្រុងកង់បេរ៉ា។ ការប្តេជ្ញាក្នុងការបង្ហាញនូវសិល្បៈរបស់ប្រទេសជិតខាងបំផុតរបស់យើង បានចាប់ផ្តើមឡើងតាំងពីពេលកំណើតនៃវិចិត្រសាលនេះ។ ប៉ុន្តែយើងមានរូបចម្លាក់ខ្មែរតិចតួចបំផុត។ កម្ចីនេះដែលជាកម្ចីពីបណ្តុំនៃស្នាដៃវិសេសលើលោកបានពង្រីកសមត្ថភាពរបស់យើងក្នុងការបង្ហាញនូវរឿងនៃសិល្បៈនៃទឹកដីអាស៊ីអាគ្នេយ៍។»

កម្ចីរយៈពេលវែងបានអនុញ្ញាតិអោយវិចិត្រសាលជាតិអូស្ត្រាលី ដាក់តាំងបង្ហាញនូវសិល្បៈខ្មែរដ៏វិចិត្រនៃសម័យមួយដ៏សំខាន់ក្នុងប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ និងបានទាញនូវចំណាប់អារម្មណ៍ជុំវិញបញ្ហាជួញដូរ ការលួច និងការផលិតឡើងវិញនូវវត្ថុបុរាណដោយខុសច្បាប់។

16B National Assembly Street, Sangkat Tonle Bassac Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

លោកជំទាវ **អាលីសុន បើរ៉ូ (Alison Burrows)** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា «ពិព័រណ៍នូវរូបចម្លាក់ដ៏អស្ចារ្យទាំងនេះ គឺជាឧទាហរណ៍មួយទៀតនៃចំណងទំនាក់ទំនងដ៏ជិតស្និទរវាងប្រទេសយើងទាំងពីរ។ ជារៀងរាល់ឆ្នាំ មានប្រជាជនអូស្ត្រាលីរាប់សិបពាន់នាក់ធ្វើដំណើរមកទីក្រុងសៀមរាប ដើម្បីទស្សនាប្រាសាទនានា។ ខ្ញុំជឿជាក់ថាប្រជាជនអូស្ត្រាលីនឹងរីករាយទស្សនានូវស្នាដៃសិល្បៈដ៏ប្រណិតរបស់ខ្មែរនៅទីក្រុងរបស់ពួកគេ ហើយការចូលរួមទស្សនានេះនឹងញ៉ាំងអោយប្រជាជនអូស្ត្រាលីច្រើនថែមទៀតមកទស្សនានៅកម្ពុជា។»

ពិព័រណ៍នេះរួមមាន ចម្លាក់ព្រះពុទ្ធរូបក្នុងឥរិយាបថឈរទ្រង់កាយវិការបង្រៀន នៃស.តទី៧ ដែលជារូបចម្លាក់មួយក្នុងចំណោមរូបចម្លាក់ព្រះពុទ្ធចំណាស់ជាងគេដែលបានរកឃើញនៅប្រទេសកម្ពុជា ផ្តែរដែលមានក្បាច់រចនាឆើតឆាយនៃស.តទី១០ដែលបង្ហាញផ្នែកមួយនៃរឿងបង្កើតលោកក្នុងសាសនាហិណ្ឌូ គឺរឿងកូរសមុទ្រទឹកដោះ និងព្រះប្រាជ្ញាបារមី ជាទម្រង់កុមារី។

ស្ថានទូតអូស្ត្រាលីភ្នំពេញ សូមសំដែងនូវអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងសារមន្ទីជាតិកម្ពុជា ដោយបានជួយជ្រោមជ្រែងពិព័រណ៍នេះអោយលេចចេញរូបរាងឡើង។

**ទំនាក់ទំនងពត៌មាន៖ លោក សាយម៉ុន ហ្វៀលឡូវស៍ អនុប្រធានបេសកកម្ម**

**ទូរស័ព្ទលេខ ០២៣ ២១៣ ៤៧០**

**ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤**